ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការពន្យារពេលនៃរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២១ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២១ របស់ រ.ទ.ស.ភ ដែលត្រូវផ្តល់ជូននិយ័តករមូលបត្រកម្ពុជា យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ នឹងពន្យារពេលដល់ **ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១** ដោយសារក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក ដែលជាសវនករឯករាជ្យរបស់ រ.ទ.ស.ភ ពុំអាចផ្តល់របាយការណ៍លើការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបសម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ តាមការព្រមព្រៀងរវាង រ.ទ.ស.ភ និងក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក បាននោះទេ។ ការយឺតយ៉ាវនេះបណ្តាលមកពីវិធានការបិទខ្ទប់របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ ១៩ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ដែលជះឥទ្ធិពលដល់ដំណើរការត្រួតពិនិត្យកិច្ចការ ជាពិសេសការផ្តល់ឯកសារសំខាន់ៗមួយចំនួនរបស់ រ.ទ.ស.ភ ជូនសវនករឯករាជ្យទាន់ពេលវេលា។ ម្យ៉ាងទៀត ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក ជាក្រុមហ៊ុនដែលធ្វើការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេប របស់ រ.ទ.ស.ភ ជាលើកដំបូង ដូច្នេះក្រុមហ៊ុនត្រូវការពេលវេលាបន្ថែម ដើម្បីសិក្សាស្វែងយល់លម្អិតពី រ.ទ.ស.ភ ។

ហេតុដូចនេះ ការពន្យារពេលក្នុងការផ្តល់របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២១ របស់ រ.ទ.ស.ភ ដោយសារការអវត្តមាននៃរបាយការណ៍លើការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបសម្រាប់ត្រីមាស និងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលជាផ្នែកសំខាន់នៃរបាយការណ៍ប្រចាំត្រីមាស។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទទួលជ្រាប។

ថ្ងៃពុធ ១កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**